ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១២៣/១៣-ណាហ្គា វើលដ៍
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ឈើវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ណាហ្គា វើលដ៍ លីមីធីត**

អាសយដ្ឋាន ៖ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៦ ៩១៩ ៤១៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖ អវត្តមាន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុន ណាហ្គា វើលដ៍**

អាសយដ្ឋាន ៖ ផ្ទះលេខ I.២, ផ្លូវសុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៩២៧ ២៨៣ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖

| | |
|---|---|
| ១- លោក សុខ ណារិទ្ធ | អ្នករងគ្រោះនៅ Naga |
| ២- កញ្ញា ឈឹម សុខន | លេខាធិការសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុន ណាហ្គា វើលដ៍ |

| | |
|---|---|
| ៣- លោក សិន សែន | រដ្ឋបាលសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍សេវាកម្មកម្ពុជា |
| ៤- លោក ឃួន ធីម | គណៈកម្មការសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គា វើលដ៏ |
| ៥- លោក សាត ស៊ិនឆៃ | គណៈកម្មការសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គា វើលដ៏ |
| ៦- កញ្ញា ញាន ចាន់ថុល | គណៈកម្មការសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គា វើលដ៏ |
| ៧- កញ្ញា កែវ កញ្ញា | គណៈកម្មការសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គា វើលដ៏ |
| ៨- លោកស្រី ហេង បុង | មេធាវី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតដែលជាសមាជិករបស់សហជីពនៅតែទាមទារឱ្យក្រុមហ៊ុន គោរពតាមសេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១០/២០១០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០, លេខ ៧៨/២០១០ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ និងសេចក្តីបង្គាប់លេខ ១៨៤/២០១២ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះចំណុចនេះ ក្រុមហ៊ុនមិនអាចយកមកអនុវត្តបានទេ ព្រោះក្រុមហ៊ុនបានប្តឹងជំទាស់ដោយអនុវត្តទៅតាមនីតិវិធីច្បាប់រួចហើយ ។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលទាបបំផុតចំនួន ១៥០ ដុល្លារ ក្នុងមួយខែ និងតំឡើងកាំប្រាក់ចំនួន ២០ ភាគរយ សម្រាប់បុគ្គលិកគ្រប់ផ្នែកដែលទទួលប្រាក់ឈ្នួលបាន ចាប់ពី ១៥០ ដុល្លារ ក្នុងមួយខែឡើងទៅ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ករណីនេះក្រុមហ៊ុនបានសុំពេលដើម្បីធ្វើការសិក្សា ឱ្យបានល្អិតល្អន់សិន តែត្រូវបានភាគីសហជីពមិនយល់ព្រម ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូក ទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការមិនសះជាលេខ ៧១៣ កប/អក/វក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ (វេលាម៉ោង ២ និង ០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារបានទទួលលិខិតមួយច្បាប់លេខ ៣៤/១៣ សទសខ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ របស់សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុន ណាហ្គា វើល ស្ដីពីការជូនដំណឹងធ្វើកូដកម្មអហឹង្សារបស់បុគ្គលិក ដើម្បីទាមទារឱ្យក្រុមហ៊ុនដោះស្រាយ និងកែលំអទូវលក្ខខណ្ឌការងារ ចំនួន ០២ ចំណុច។ បន្ទាប់ពីបានទទួលបណ្ដឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នា ចំនួន ០២ ចំណុច លើការទាមទារចំនួន ០២ ចំណុច។ ចំណុចមិនសះជា ចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃ ទី១៩ ខែមិថុនា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមលេខ ៧១៣ កប/អក/វក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

តាមរយៈដីកាសម្រេចរក្សាការពារលេខ ០៩ ណ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ ដែលភាគីនិយោជកបានផ្ដល់ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា បុគ្គលិកបានចាប់ផ្ដើមធ្វើកូដកម្មនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលដំណឹងពីភាគីកម្មករនិយោជិតថា កូដកម្មនៅតែបន្តនៅក្រុមហ៊ុន ណាហ្គា វើល បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាលនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៣ នៅវេលាម៉ោង ១៤៖០០ នាទី រសៀល។ ភាគីកម្មករនិយោជិតមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ប៉ុន្តែ ភាគីនិយោជកមិនមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ។

ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ នៅវេលាម៉ោង ១៤៖០០ នាទី រសៀល ភាគីកម្មករនិយោជិតបានអះអាងថា នាពេលបច្ចុប្បន្ន បុគ្គលិកចំនួនប្រមាណជា ៨០០ នាក់ កំពុងបន្តធ្វើកូដកម្ម។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- ដីកាសម្រេចរក្សាការពារ លេខ ០៩ "ណ" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

២- ដីកាសម្រេចអនុវត្តជំនួស លើសំណុំរឿងរដ្ឋប្បវេណី លេខ ២១៨ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ លេខ ៦២៣ ត.រ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣- ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ របស់ឈ្មោះ ឈឹម ស៊ីថរ គោរពចូលមក ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ ស្តីពីសុំតវ៉ាដីការសម្រេចរក្សាការពារលេខ ០៩ "ណ" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ នៃសំណុំរឿងរក្សាការពារលេខ ២៩០ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ របស់ សាលាដំបូងរាជធានីភ្នំពេញ។

៤- ដីកាសម្រេច លេខ ១០៤៥ ត.រ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

៥- ពាក្យសុំផ្អាកការអនុវត្ត ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ របស់ឈ្មោះ ឈឹម ស៊ីថរ គោរពចូលមក ឯកឧត្តមប្រធានសាលាដំបូង រាជធានីភ្នំពេញ ស្តីពីសុំផ្អាកការអនុវត្តចំពោះដីកាសម្រេចរក្សាការពារ លេខ ០៩ "ណ" ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ នៃសំណុំរឿងរក្សាការពារលេខ ២៩០ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ របស់ សាលាដំបូងរាជធានីភ្នំពេញ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គា វើលដ៏ (ខេមបូឌា) លេខ ៧១៣ កប/អក/វក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គា វើលដ៏ (ខេមបូឌា) ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៦២២ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦២៣ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលមានបញ្ជាក់នៅក្នុងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមលេខ ៧១៣ កប/អក/វក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបន្តដំណើរការអាជ្ញាកណ្តាល ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *"ក្នុងអំឡុងពេល នៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"* ។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤ - អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

*"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម"*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤ - សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វែល ប្រែព្ល ឌិ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

"ចំណុចទី៩ - ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ" ។

"ចំណុចទី១១ - ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគី

ណាមួយបំពានប្រការណាមួយនៃសេចក្ដីបញ្ជានេះ" ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥ - ហ្វ្រង់កូ ទីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ១១០/១១ - ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣ - អ៊ិនធើណាស្យូណាល់ ហ្វេសិន រ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏បានចេញសេចក្ដីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្ដាល ដោយមូលហេតុកម្មករនិយោជិតនៅបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងខាងលើដែរ ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែមទៅលើករណីកូដកម្មនេះ ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាលនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ នៅវេលាម៉ោង ១៤៖០០ នាទី រសៀល ។ តាមរយៈកិច្ចប្រជុំនេះ ភាគីកម្មករនិយោជិតបានអះអាងថា នាពេលបច្ចុប្បន្ន បុគ្គលិកចំនួនប្រមាណជា ៨០០ នាក់ កំពុងបន្តធ្វើកូដកម្ម ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច មិនបន្តដំណើរការអាជ្ញាកណ្ដាលនៃសំណុំរឿងលេខ ១២៣/១៣ - ណាហ្គា វើល នេះទេ ។

យោងតាមអង្គច្បាប់ និងហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចដូចតទៅ ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ១២៣/១៣ - ណាហ្គា វើលដ៏ ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **ឈឹម គិរម្យ**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល ៖**

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា ៖ ------------------------------